10/1

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ហលាដំបូងរាជធានីភ្នំពេញ

ប់ណុំរឿងព្រហ្មទណ្ឌលេខ
១១៩ ចុះថ្ងៃទី១៨ ខែ
មិថុនា ឆ្នាំ ២០០៨
ហលក្រមលេខ៥៨ កប៣ "ធ"
ក្រ៣ចុះថ្ងៃទី១៩ -៥- ២០១០

## ពាក្យនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី០៤-៥-២០១០ ដល់ថ្ងៃទី ១៩-៦-២០១០ ។

ដោយមានសមាសភាពដូចតទៅ :

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

លោកស្រី [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជ

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ១១១៩ចុះថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ២០០៨ ដែលមានជនជាប់ចោទ :

១-/ឈ្មោះ [redacted] រតនៈ ភេទប្រុសអាយុ១៩ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] សង្កាត់ ទួលសង្កែ ខណ្ឌ ឫស្សីកែវ រាជធានី ភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" សិស្សវប្បធម៌ថ្នាក់ទី៧ ចាប់ខ្លួនថ្ងៃទី១៧ -៦-២០០៨ ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧១០ត.ព្រ ចុះថ្ងៃទី ២០-៦-២០០៨ ។

២-ឈ្មោះ [redacted] សុភាវុធ ភេទប្រុស អាយុ២១ឆ្នាំ កើតនៅសង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ មានទីលំនៅមុនពេលចាប់ខ្លួន [redacted] សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបររកស៊ីសិស្សវិទ្យាល័យ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-១២-២០០៩ ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៣៣១០ត.ព្រ ចុះថ្ងៃទី ២៩-១២-២០០៩ ។

**ជាប់ចោទពីបទ** : ប្លន់ ( ម៉ូតូ ) ប្រព្រឹត្ត នៅចំណុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៧-៦-០៨ តាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។



Scanned by CamScanner

-ជនរងគ្រោះឈ្មោះ [redacted] ចាន់ណាភេទប្រុសជាតិខ្មែរកើតនៅឆ្នាំ១៩៨០មានទីលំនៅផ្ទះលេខ២៣៥ផ្លូវមុន្នីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរសិស្ស ។

-មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] រតនៈ គឺ លោក [redacted] អង

-មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] សុភារ៉ុធពី លោកស្រី [redacted] ធីតា .លោកស្រី [redacted] រត្នមុន្នី .លោក [redacted] តុលា

<u>ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ:</u>

កាលពីថ្ងៃទី ១៧-៦-០៨ នៅចំណុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិសង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណីប្លន់( វាយយកម៉ូតូ) មួយកើតឡើងដែលបង្កឡើងដោយជនល្មើសឈ្មោះ [redacted] តនះ និង ឈ្មោះ [redacted] សុភារ៉ុធព្រមទាំងបក្សពួក៦នាក់ទៀតបានធ្វើសកម្មភាពវាយយកម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] ចាន់ណា បណ្តាលឱ្យជនរងគ្រោះត្រូវរបួសភ្នាមនោះជនរងគ្រោះក៏បានផ្តួលម៉ូតូចោល ហើយរត់គេចខ្លួន ហើយជនល្មើសឈ្មោះ [redacted] រតនៈ ប៉ុនប៉ងលើកម៉ូតូជនរងគ្រោះជិះចេញក៏ត្រូវសមត្ថកិច្ចមកដល់ឃាត់ខ្លួនបានឈ្មោះសោមរតនៈរីឯបក្សពួករបស់ជនល្មើសផ្សេងទៀតបានរត់គេចខ្លួនអស់តែម្តង ។

-បានឃើញរបាយការណ៍សំយោគលេខ ០៩៧/២០០៨ ចុះថ្ងៃទី ២២-៦-២០០៨ របស់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ១៥៣៤ អ.យ.ងចុះថ្ងៃទី២១ ខែសីហា ឆ្នាំ ២០០៩ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះ លេខ ១៤៦៥២ តព្រចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៨ និង លេខ១៥៣៣៣ ត.ព្រចុះថ្ងៃទី២២-៩-២០០៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសាលក្រមរបៀបលេខ០២ក្រ៣ ចុះថ្ងៃទី១០-០២-២០០៩ របស់ក្រុមប្រឹក្សាជំនុំជំរះសាលាដំបូងរាជធានីភ្នំពេញ ។

## <u>ពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] រតនៈបានឆ្លើយថា:ជនរងគ្រោះស្រែកឱ្យខ្លួន១ក៏ចុះទៅវាយជនរងគ្រោះដោយមិនបានយកម៉ូតូគេទេ មាស សុភារ៉ុធមិនបានវាយជាមួយខ្លួនទេ ជិះគ្នាពីរម៉ូតូ [redacted] សុភារ៉ុធ ឥតទៅទេ ។

នៅថ្ងៃទី១៧-៦-២០០៨ វេលាម៉ោងមួយកណ្តាលយប់ គេស្រែកឱ្យខ្លួន១ក៏ចុះវាយមិនបានយកម៉ូតូគេទេពេលវាយប៉ូលីសនៅជិតនោះដែរ មុនចាប់ខ្លួន ខ្លួនរកស៊ីថតរូបឱ្យគេ ។ ខ្លួនបានវាយគេមែន តែមិនបានយកម៉ូតូគេទេ ។ ចម្លើយខ្លួននៅសមត្ថកិច្ចប៉ូលីស- អយ្យការ និងនៅចៅក្រមស៊ើបសួរ ខ្លួនមិនទទួលស្គាល់ទេ ខ្លួនបានវាយគេមែនតែមិនបានយកម៉ូតូគេទេ ខ្លួនយកខ្សែក្រវ៉ាត់វាយគេ ។

ខ្លួនបានចេញពីផឹកស៊ីនៅចូលគោកជិះម៉ូតូពីរគ្រឿង ពេលមកដល់មុខវាំងគេស្រែកជេរខ្លួន១ក៏ត្រឡប់ក្រោយវិញចុះវាយ ឈ្មោះហ៊ាងជាអ្នកឌុប អាហ៊ាងជិះចេញទៅបាត់ ហើយ សុភារ៉ុធមិនបានទៅទេ ខ្លួនស្គាល់នៅកន្លែងផឹកស៊ី ។ ខ្លួនទៅជិះម៉ូតូពីរគ្រឿងមានគ្នាបួននាក់ គឺ :អាហ៊ាង , អាចយ ,អារាជ, និង រូបខ្លួន [redacted] សុភារ៉ុធមិនទៅជាមួយខ្លួនទេ

ខ្ញុំបានវាយតែមែនព្រោះគេជេរខ្លួនខ្ញុំមិនមានបំណងយកម៉ូតូគេទេ វាយរួចគេទៅអស់នៅសល់តែខ្លួនក៏ត្រូវសមត្ថកិច្ចចាប់បាន ។

-ជនជាប់ចោទឈ្មោះ [redacted] សុភាវុធ បានឆ្លើយថា : នៅថ្ងៃកើតហេតុខ្លួនបានទៅញាំអីនៅទួលគោកមានឈ្មោះចាន់ថា . រីណា. ខ្លួនមិនបានទៅជាមួយឈ្មោះ រតន: .អាចយ. អាហ៊ាង និង អាភាជទេ ខ្លួនមិនដែលធ្លាប់ស្គាល់រតន:ទេ ថ្ងៃកើតហេតុយូរពេកខ្លួនមិនចាំពួកខ្លួនចេញពីហាងទេ ពួកខ្លួនជិះចេញតាមសួនសម្តេចហ៊ុន សែនឃើញករណីមួយកើតឡើង ខ្លួនក៏ជិះទៅផ្ទះ ពេលផឹកស៊ី ខ្លួនផឹកស៊ីគ្នាបីនាក់ ហើយខាងឈ្មោះរតន: ផឹកគ្នាបួននាក់ ទៅប្រាំនាក់ប៉ូលិសចាប់ខ្លួននៅពេលខ្លួន កំពុងសរសេរមេរៀននៅផ្ទះ ។ គេចាប់ខ្លួននៅថ្ងៃទី២៨-១២-២០០៩ ហើយថ្ងៃទី ១៧-៦-២០០៨ ខ្លួនបានផឹកស៊ីជាមួយពួកម៉ាកនៅម៉ោងប្រហែលដប់កន្លះយប់ ដើរលេងរហូតដល់ម៉ោង១១យប់ ខ្លួនឃើញមានកើតហេតុខ្លួនក៏ទៅផ្ទះទៅខ្លួនមិនស្គាល់សោម រតន:នេះទេពេលជល់កែវខ្លួនធ្លាប់ឃើញ តែខ្លួនមិនបានចូលរួមគុជាមួយពួកគេទេពេលចេញក្រុមរតន:ចេញទៅមុនពួកខ្លួនចេញទៅតាមក្រោយខ្លួនមិនបានចាំម៉ោងច្បាស់ទេ នៅពេលកើតហេតុខ្លួនមិនបានឃើញមុខឈ្មោះរតន:នេះទេ ខ្លួនឃើញតែប៉ូលីសនៅពេញទីនោះ ពេលកើតហេតុខ្លួនបានជិះកាត់តាមកន្លែងកើតហេតុនោះដែរ ។

ខ្លួនមិនបានប្រព្រឹត្តទេ គេចាប់ខ្លួននៅផ្ទះមិនដឹងមូលហេតុទេ គេថាចាប់ខ្លួនតាមដីកា ។ ពេលផឹកស៊ីគុផ្សេងគ្នាចេញប្រាក់ផ្សេងគ្នា ពេលកើតហេតុឃើញមានប៉ូលីស តែពុំដឹងមានរឿងអ្វីទេ ។

-ក្រឡាបញ្ជីអានចំលើយជនរងគ្រោះឈ្មោះ [redacted] ចាន់ណា ថា : កាលពីថ្ងៃទី១៧-៦-២០០៨ វេលាម៉ោងមួយ និង ដប់នាទីរំលងអាធ្រាតខ្ញុំ និង មិត្តភក្តិចំនួន៦នាក់ទៀតបានមកផឹកស៊ីនៅហាងមួយកន្លែងម្តុំផ្សារចាស់មិនស្គាល់ឈ្មោះហ៊ាង ពេលផឹកស៊ីរួចក៏នាំគ្នាចេញទៅផ្ទះរៀង១ខ្លួន ចំពោះរូបខ្ញុំ និង មិត្តម្នាក់ទៀតបានជិះម៉ូតូមួយគ្រឿងពីរនាក់ក្នុងគោលបំណងត្រឡប់មកផ្ទះវិញតាមផ្លូវព្រះស៊ីសុវត្ថិពីទិសខាងជើងមកទិសខាងត្បូង លុះមដល់ចំណុចជិតព្រះអង្គដងកើស្រាប់តែមានជនល្មើសជិះម៉ូតូបីគ្រឿងមិនស្គាល់ម៉ាកមានគ្នាប្រាំពីរនាក់មកធ្វើសកម្មភាពប្លន់ម៉ូតូវាយខ្ញុំ និងមិត្តខ្ញុំបណ្តាលឱ្យមានរបួសផ្នែកខាងខ្នង និងដៃឆ្វេងពេលនោះក៏មានសមត្ថកិច្ចប៉ុស្តិ៍ប្រចាំការនៅព្រះអង្គដងកើបានមកជួយធ្វើអន្តរាគមន៍ចាប់ជនបង្កល្មើសបានម្នាក់ និង វត្ថុតាងយកមកកាន់ទីស្នាក់ការប៉ុស្តិ៍ជ័យជំនះតែម្តង ចំនែកបក្សពួកប្រាំមួយនាក់ទៀតបានរត់គេចខ្លួនបាត់រស់ទៅ ។

**សំណូមពរ** : សូមឱ្យសមត្ថកិច្ចផ្តន្ទាទោសអ្នកបង្កទៅតាមច្បាប់ និងស្វែងរកចាប់បក្សពួកវា ដែលបានរត់គេចខ្លួនមកផ្តន្ទាទោស ។

## <u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>

ឆ្លងតាមអង្គសវនាការឃើញថា : ពេលកើតហេតុគឺនៅវេលាម៉ោងមួយរំលងអាធ្រាត្រក្រុមជនល្មើសមានគ្នាដល់ទៅ៧នាក់បានរៀបចំគំរោងប្លន់ដោយមានអ្នកជិះម៉ូតូ មានអ្នកវាយម្ចាស់ម៉ូតូ និង អ្នកយកម៉ូតូពីជនរងគ្រោះលុះពេលធ្វើដំណើរបកដល់ចំណុចព្រះអង្គដងកើក៏ចាប់ធ្វើសកម្មភាពប្លន់ទៅលើជនរងគ្រោះប្រាកដមែន ។

ដូចនេះរាល់សកម្មភាពរបស់ក្រុមជនល្មើសជារូបភាពប្លន់ដែលមានកើតឡើងជាច្រើននៅទីក្រុងភ្នំពេញ ហើយជនល្មើសឈ្មោះ [redacted] រតន: និង ឈ្មោ [redacted] សុភាវុធនេះមានកាយទីតិសម្បទាគ្រប់គ្រាន់ក្នុងការប្រព្រឹត្តបទល្មើស ។



Scanned by CamScanner

ដូចនេះតំណាងអយ្យការសូមតម្កល់ការចោទប្រកាន់នៅដដែលសុំអោយតុលាការសំរេចផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

សេចក្តីសន្និដ្ឋានរបស់លោកមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ[redacted] រតនៈ

ផ្អែកតាមអង្គសវនាការឃើញថាកូនក្តីខ្ញុំឈ្មោះ [redacted]រតនៈ ពិតជាបានឈ្លោះទាស់ទែង ជាមួយជនរងគ្រោះ មានការវាយតប់ទៅលើជនរងគ្រោះប្រាកដមែន ដោយហេតុថាកូនក្តីខ្ញុំស្រវឹងស្រាហើយពួកគេថាអោយខ្ញុំក៏មានការប្រទេសរាយក្តៅឡើងដោយភាន់ច្រឡំពុំបានពិនិត្យមើលថាបានយកទ្រព្យសម្បត្តិរបស់គេទេហើយម៉ូតូដែល ដូចគឺទៅប្លន់ដដែល កូនក្តីខ្ញុំពុំបានទៅយកម៉ូតូនោះទេពីកូនក្តីខ្ញុំគ្រាន់តែបានបោតជ្រោះលើម៉ូតូនោះដើម្បីធ្វើការរត់គេចខ្លួនចេញពីសមត្ថកិច្ចប៉ុណ្ណោះ ។

ដូចនេះការចោទប្រកាន់របស់តំណាងអយ្យការ សុំអោយតុលាការមេត្តា ពិនិត្យពិចារណាលើអំពើប្រព្រឹត្តរបស់កូនក្តីខ្ញុំ សុំអោយសំរេចកែប្រែបទចោទពីបទប្លន់ ទៅបទបង្ករបួសស្នាមវិញ ។

**សេចក្តីសន្និដ្ឋានរបស់លោកមេធាវី[redacted]ធីតា ការពារឱ្យជនជាប់ចោទឈ្មោះមាស សុភារុធ**

ផ្អែកតាមការស៊ើបអង្កេត និង អង្គសវនាការឃើញថាកូនក្តីខ្ញុំពុំបានទៅចូលរួមប្រព្រឹត្តរបស់ពួកគេឡើយ គឺកូនក្តីខ្ញុំគ្រាន់តែបានទៅផឹកស៊ីជួបជាមួយមិត្តភក្តិឈ្មោះរតនៈប៉ុណ្ណោះ ហើយកូនក្តីខ្ញុំមិនបានចូលរួមប្រព្រឹត្តជាមួយឈ្មោះរតនៈឡើយ ហើយជាក់ស្តែងម៉ូតូជនរងគ្រោះបានទទួលវិញហើយ ម្យ៉ាងទៀតនៅទៅពេលតុលាការកោះហៅឱ្យចូលមកដោះស្រាយ ជនរងគ្រោះ និង សាក្សីមិនបានចូលមកដោះស្រាយតាមការកោះហៅរបស់តុលាការឡើយ ។

ដូចនេះសុំឱ្យតុលាការសំរេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទ ។

- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ[redacted]រតនៈ: ខ្ញុំបានវាយគេមែនព្រោះគេស្រែកអោយខ្ញុំតែខ្ញុំមិនបានប្លន់យកម៉ូតូគេទេ ខ្ញុំសុំសំណូមពរសុំអោយតុលាការកែប្រែបទចោទពីពីបទប្លន់ ទៅបទបង្ករបួសស្នាមវិញ ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ[redacted] សុភារុធៈ សុំឱ្យតុលាការលើកលែងចោទប្រកាន់ឱ្យខ្ញុំបានទៅរៀនសូត្រវិញ ។

**សំអាងហេតុ**

-ក្រោយពីបានស្តាប់ចំលើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចំលើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចំលើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យពិចារណា និង ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយឃើញថា

-យល់ឃើញថាៈ តាមរបាយការណ៍សំណុំរឿងលេខ ០៩៧ /២០០៨ ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០០៨ បញ្ជាក់ឱ្យឃើញថា : កាលពីថ្ងៃទី១៧-៦-០៨នៅចំណុចព្រះអង្គដងកើផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញមានករណីវាយឆក់ម៉ូតូមួយកើតឡើង ដែលបង្កឡើងដោយជនល្មើសឈ្មោះ[redacted] រតនៈ និង បក្សពួកជាច្រើននាក់ទៀត បានធ្វើសកម្ម



Scanned by CamScanner

ភាពវាយទៅលើម្ចាស់ម៉ូតូឈ្មោ[redacted]ចាន់ណាយកម៉ូតូក្នុងខណៈពេលកំពុងធ្វើសកម្មភាពប្លន់ជនរងគ្រោះក៏បានផ្តួលម៉ូតូរត់គេចខ្លួនពេលនោះជនល្មើសឈ្មោះ [redacted] រតនៈ បំរុងលើកម៉ូតូជនរងគ្រោះយករត់ក៏ត្រូវបានសមត្ថកិច្ចមកទាន់ឃាត់ខ្លួនបានឈ្មោះ[redacted] រតនៈ រីឯបក្សពួកផ្សេងទៀតក៏បានឡើងជិះម៉ូតូគេចខ្លួនអស់ ។

-យល់ឃើញថា :តាមចំលើយបំភ្លឺរបស់សាក្សីឈ្មោះ[redacted] មករាបានបញ្ជាក់ថាកាលពីថ្ងៃទី១៧-៦-០៨វេលាម៉ោងមួយយប់ខ្លួន និង ឈ្មោះចាន់ណាបានចេញពីកន្លែងហូបចុកនៅម្តុំផ្សារចាស់ ជិះម៉ូតូឌុបគ្នាកាត់តាមមុខវាំងតាមផ្លូវមាត់ទន្លេ ដល់កន្លែងវេទិកាបុណ្យអុំទូកស្រាប់តែមានជនល្មើសមួយក្រុមមានគ្នាប្រហែល៥ទៅ៦នាក់ជិះម៉ូតូ៣គ្រឿងមកអែបហើយវាយប្លន់យកម៉ូតូតែម្តងដោយពួកវាបានយកខ្សែក្រវ៉ាត់វាយមកលើពួកខ្លួន ពេលនោះមិត្តភក្តិខ្លួនក៏បានផ្តួលម៉ូតូរត់គេចខ្លួនហើយជនល្មើស [redacted] រតនៈ លើកម៉ូតូបំរុងជិះរត់ក៏ត្រូវសមត្ថកិច្ចប្រចាំការនៅទីនោះឃាត់ខ្លួនបានជនល្មើសមួយនាក់ឈ្មោ[redacted]តនៈនិងម៉ូតូជនរងគ្រោះរីឯបក្សពួកជនល្មើសផ្សេងទៀតក៏បានជិះម៉ូតូរត់គេចខ្លួនបាត់អស់ ។

ដើមបណ្តឹងឈ្មោ[redacted] ចាន់ណាបានឆ្លើយបញ្ជាក់ថាកាលពីថ្ងៃទី ១៧-៦-០៨វេលាម៉ោង១ និង ១០នាទីយប់ខ្លួននិងមិត្តភក្តិម្នាក់ទៀតឈ្មោ[redacted] មករាបានជិះម៉ូតូត្រឡប់ពីផ្សារចាស់ទៅផ្ទះវិញពេលទៅដល់កន្លែងកើតហេតុមានជនល្មើសមួយក្រុមជិះម៉ូតូ៣គ្រឿងបាននាំគ្នាវាយមកលើខ្លួននិងមិត្តខ្លួនយកម៉ូតូ បណ្តាលអោយខ្លួន និង មិត្តខ្លួនត្រូវរបួសភ្លាមនោះសមត្ថកិច្ចនៅទីនោះក៏បានមកជួយអន្តរាគមន៍ចាប់បានជនល្មើសម្នាក់ឈ្មោះ[redacted] រតនៈ និងម៉ូតូ រីឯបក្សពួកជនល្មើសផ្សេងទៀតក៏បានឡើងជិះម៉ូតូគេចខ្លួនអស់ ។

-យល់ឃើញថា:ជនល្មើសឈ្មោ[redacted] រតនៈបានឆ្លើយសារភាពនៅសមត្ថកិច្ចប៉ូលីសថា:កាលពីថ្ងៃទី ១៧-៦-០៨វេលាម៉ោងមួយយប់រំលងអាធ្រាតខ្លួននិងបក្សពួក៧នាក់ទៀតជិះម៉ូតូ៤គ្រឿង បានធ្វើសកម្មភាពវាយប្លន់យកម៉ូតូជនរងគ្រោះដែលកំពុងជិះប្រាកដមែន គឺមានឈ្មោះហ៊ាង .ឈ្មោះរាជ . ឈ្មោះចយ . និងឈ្មោះវុធ គូកន៣នាក់ទៀតមិនស្គាល់ឈ្មោះ ប្រវត្តិរូបរបស់ ឈ្មោះវុធតុលាការបង្ហាញមានរូបថតនេះពិតជាឈ្មោះវុធ បានជិះម៉ូតូទៅជាមួយពួកខ្លួនមែន ដែលចំលើយនេះមានការស៊ីសង្វាក់ទៅនឹងចំលើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីដែលបានបំភ្លឺ ។

-យល់ឃើញថា :តាមការឆ្លើយបំភ្លឺ របស់ជនជាប់ចោទឈ្មោះ[redacted] រតនៈ នៅពេលសវនាការនេះថា ខ្លួនពិតជាបានទៅវាយជនរងគ្រោះប្រាកដមែនព្រោះជនរងគ្រោះបានស្រែកជេរខ្លួន តែខ្លួនមិនបានទៅយកម៉ូតូរបស់គេទេហើយនៅពេលនោះឈ្មោះ[redacted]សុភាវុធ ពុំបានចូលរួមជាមួយខ្លួនទេ ។

-យល់ឃើញថា: តាមចំលើយរបស់ជនជាប់ចោទឈ្មោះ[redacted]សុភាវុធ នៅពេលសវនាការនេះថា : ខ្លួនមិនបានចូលរួមវាយតប់ជាមួយឈ្មោះ[redacted] រតនៈទេ ហើយខ្លួនក៏មិនបានស្គាល់ឈ្មោះ [redacted] រតនៈដែរ ខ្លួនគ្រាន់តែបានជួបមុខឈ្មោះ[redacted] រតនៈ នៅកន្លែងស៊ីផឹកតែប៉ុណ្ណោះ ខ្លួនមិនបានដឹងរឿងអ្វីទេ ។

-យល់ឃើញថា: តាមចំលើយរបស់ជនជាប់ឈ្មោះ [redacted]រតនៈ និង ឈ្មោះ [redacted]សុភាវុធ ដែលបានឆ្លើយនៅពេលសវនាការនេះ មិនអាចភស្តុតាងណាមួយអាចអោយគុណភាពការជឿបានឡើយ ព្រោះជាចំលើយរបស់ជនជាប់ចោទឈ្មោះ[redacted] រតនៈនៅប៉ូលីសថាខ្លួនចេញពីកន្លែងស៊ីផឹកជិះម៉ូតូតាមផ្លូវមាត់ទន្លេមានម៉ូតូ៤គ្រឿង មានគ្នា៧នាក់ ស្របទៅតាមចំលើយបំភ្លឺរបស់សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្ទុយទៅនឹងចំលើយនាពេលសវនាការនេះថាខ្លួនទៅតែម៉ូតូពីរគ្រឿង មានគ្នាបួននាក់ ។



Scanned by CamScanner

-យល់ឃើញថា: អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រតនៈ និង ឈ្មោះ [redacted] សុភាវុធ ដែលបានធ្វើសកម្មភាព វាយជនរងគ្រោះយកម៉ូតូដោយគ្មានការយល់ព្រមពីម្ចាស់ទ្រព្យនោះ បានបំពានទៅនឹងមាត្រា ៦នៃច្បាប់ស្តីពីស្ថានទំងន់ ទោសនៃបទឧក្រិដ្ឋ ។

មាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋចែងថា : អំពើប្លន់ជាការបន្លំ និង ជាការជំរិតយកទ្រព្យសម្បត្តិអ្នកដទៃ តាមគ្រប់រូបភាពដោយផ្ទាល់ក្តី ដោយប្រយោលក្តី ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

-យល់ឃើញថា : ទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] រតនៈ និង ឈ្មោះ [redacted] សុភាវុធ ដែលបានវាយទៅលើជនរងគ្រោះនឹងខ្សែក្រវ៉ាត់យកម៉ូតូនោះ បានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ជាពិសេសធ្វើអោយប៉ះពាល់ដល់និត្យានុកូលភាពសង្គម ដែលច្បាប់បានការពារ ។

-យល់ឃើញថា : ជនជាប់ចោទឈ្មោះ [redacted] រតនៈភេទប្រុស អាយុ១៩ឆ្នាំ និង ឈ្មោះ [redacted] សុភាវុធ ភេទប្រុស អាយុ២១ឆ្នាំ ជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ ។

-យល់ឃើញថា: មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គាន់លើឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ ១៩ឆ្នាំ និង ឈ្មោះ [redacted] សុភាវុធ ភេទប្រុស អាយុ ២១ឆ្នាំ ពីបទប្លន់ ( ម៉ូតូ ) ប្រព្រឹត្ត នៅចំណុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទា ទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

-យល់ឃើញថា: ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ណា បានទទួលយកម៉ូតូវិញហើយពុំទាមទារអ្វីផ្សេងទៀតទេ តុលាការពុំគប្បីលើកយកចំណុចនេះមកធ្វើការពិចារណាឡើយ តែការស្នើសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ តុលាការនឹងធ្វើការសំរេចទៅតាមច្បាប់ ។

## <u>ហេតុដូច្នេះសំរេច</u>

១-<u>ផ្តន្ទាទោស</u> :

ក-/ឈ្មោះ [redacted] រតនៈភេទប្រុសអាយុ១៩ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនពេលចាប់ខ្លួន [redacted] ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌ ឫស្សីកែវ រាជធានី ភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ស ម្តាយ ឈ្មោះ [redacted] ស កិរិតវប្បធម៌ថ្នាក់ទី ៧ ទោសពីមុនគ្មាន ។

ខ-ឈ្មោះ [redacted] ភាវុធ ភេទប្រុសអាយុ២១ឆ្នាំ មានទីលំនៅមុនពេលចាប់ [redacted] ភូមិ៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបររកស៊ីសិស្សវិទ្យាល័យឪពុកឈ្មោះ [redacted] រ ម្តាយឈ្មោះ [redacted] រ នៅលីវ ទោសពីមុនគ្មាន ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់**៦ឆ្នាំ** គិតពីថ្ងៃឃុំខ្លួន ពីបទប្លន់ ( **ម៉ូតូ** ) ប្រព្រឹត្ត នៅចំណុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

២- សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ០៤-៥-២០១០ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី១៩-៥-២០១០ ចំពោះ



Scanned by CamScanner

មុខជនជាប់ចោទឈ្មោះ [redacted] រតនះ . ឈ្មោះ [redacted] សុភារ៉ុធ និង មេធាវីការពារជនជាប់ចោទលោក [redacted] ជី:អេង .លោកស្រី [redacted] ធីតា កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ចាន់ណា ។

- បើកផ្លូវប្តឹងទាស់ និង ឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|---|
| ហត្ថលេខានិង ត្រា: [redacted] | .ហត្ថលេខា: [redacted] | . ហត្ថលេខា: [redacted] | . ហត្ថលេខា និង ត្រា [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner